# ជំងឺលើដំណាំស្រូវ

# (Diseases on Rice crop)

# លក្ខណៈទូទៅរបស់ជំងឺ

- ជំងឺ គឺជាភាពប្រែប្រួលការលូតលាស់របស់រុក្ខជាតិខុសពីលក្ខណៈធម្មតា

- ជំងឺមួយអាចកើតមានឡើងដោយសារកត្តា ៣យ៉ាងរួមផ្សំគ្នា គឺ
  - ➢ មេរោគ (ភ្នាក់ងាបង្ករោគ )
  - ➢ បរិយាកាស (បរិស្ថាន )
  - ➢ រុក្ខជាតិ (ជំរក )

# ភ្នាក់ងារបង្កជំងឺលើរុក្ខជាតិមាន

**១-ភ្នាក់ងារមានជីវិត (ជំងឺឆ្លង)**

- ពួកផ្សិត
- បាក់តេរី
- វីរុស
- ណេម៉ាតូដ

**២-ភ្នាក់ងាគ្មានជីវិត (ជំងឺមិនឆ្លង)**

- ការលើសសារធាតុចិញ្ចឹម
- ការខ្វះសារធាតុចិញ្ចឹម
- ការពុលសារធាតុផ្សេងៗ

# ជំងឺបណ្ដាលមកពីផ្សិត

## ជំងឺប្លាស(Rice blast)

- រោគសញ្ញា

• លើស្លឹក មានស្នាមចំណុចរាងពងក្រពើពណ៌ត្នោតប្រផេះ ផ្នែកកណ្ដាលមានពណ៌ប្រផេះ ហើយជាយខាងពណ៌ត្នោតរាងស្រួចចុងសងខាងសណ្ឋានដូចភ្នែកមនុស្ស ។ ចំណុចអាចរីកលូតវែងរលាយចូលគ្នា ។ បើរាលដាលដល់ស្រទបស្លឹកអាចបណ្ដាលអោយស្លឹកងាប់ ក្នុងករណីធ្ងន់ធ្ងរស្រូវមិនចេញកួរ ។




- លើដើម និង កួរ

មានចំណុចខ្មៅនៅថ្នាំងតូចៗរាងខូង រីករាលដាលលឿន រលួយ បាក់ងាប់។ កួរស្រូវអាចមានពណ៌ស គ្មានដាក់គ្រាប់ ចំណុចខ្មៅអាចកើតលើគ្រាប់ ស្វែង

- ភ្នាក់ងារបង្ក គឺបង្កដោយផ្សិតឈ្មោះ Pyricularia oryzae
- ប្រភពចំលង តាមរយៈ គ្រាប់ពូជ កាកសំណល់រុក្ខជាតិ ស្មៅអំបូរក្រាមីណេ (Gramineae) ។

## ➢ វិធានការការពារ

- ដាំពូជធនមាន IR36 IR42 IR64 IR60
- គួរបាចជីអាហ្ស៊ូតជាមួយជីផូស្វាត
- ភ្ជួរលប់គល់ជញ្ជ្រាំងក្រោយពេលប្រមូលផល
- សំអាតស្មៅក្នុងស្រែ លើភ្លឺ និងក្នុងប្រឡាយ
- អាចប្រើថ្នាំសំលាប់ផ្សិត (Fungicide) ក្នុងករណីធ្ងន់ធ្ងរ Benlat-2Kg/ha ឬ Zineb-3Kg/ha ត្រូវបាញ់មុនពេលស្រូវចេញផ្កា

## ➢ **ជំងឺអុចត្នោត** (Brown Spots)

- **រោគសញ្ញា**
  - កើតលើស្រទបស្លឹក និងសំបកគ្រាប់
  - លើស្រទបសឹកមានស្នាមចំណុចពណ៌ត្នោតរាងមូល ឬរាងពងក្រពើ។
  - លើស្លឹកចំនុចរាងមូល ឬទ្រវែងសណ្ឋានដូចគ្រាប់ល្ង
  - ចំនុចតូចៗពណ៌ត្នោត ឯស្នាមធំៗពណ៌ត្នោតចាស់នៅតែមផ្នែកកណ្តាលលឿងភ្លាវ សស្រអាប់ ឬប្រផេះ។




- ភ្នាក់ងារបង្កជំងឺ ជំងឺនេះបង្កដោយផ្សិតឈ្មោះ Helminthos porium oryzae
- ការឆ្លងរាលដាល ផ្សិតជ្រៀតចូលក្នុងរុក្ខជាតិតាមអេពីឌែម និងតាមរន្ធស្តូម៉ាតរបស់ស្លឹក ផ្សិតរាលដាលខ្លាំងពេលសីតុណ្ហភាព 20-25 អង្សាសេនិង សំណើមខ្ពស់ជាង ៩0% ដីស្ងួត
ដីខ្វះជាតិអាហ្សូត អាចអោយស្រូវឆាប់ទទួលជំងឺនេះ។
គ្រាប់កាកសំណល់រុក្ខជាតិដែលមានសសៃមីសេល្យូម និងស្មៅជាភ្នាក់ងារចំលងជំងឺយ៉ាងសំខាន់។

- **វិធានការការពារ និង កំចាត់**

  • ដាំពូជធន់នឹងជំងឺ (ដូចជំងឺប្លាស)
  • ធ្វើអនាម័យស្រែបំបាត់ជំរករបស់ផ្សិត (ស្មៅ កាកសំណល់រុក្ខជាតិ)
  • ភ្ជួរលប់ ឬដុតគល់ជញ្រ្ជាំងក្រោយពេលមានកើតជំងឺរាតត្បាតខ្លាំង
  • បញ្ចូលទឹកនៅពេលស្រូវដុះពន្លក
  • សំអាតគ្រាប់ពូជដោយយកគ្រាប់ពូជទៅត្រាំទឹក២៤ម៉ោងរួចកំដៅនៅសីតុណ្ហភាព ៥៣-៥៧ អង្សាសេ រយៈពេល១០នាទី រួចធ្វើអោយគ្រាប់ត្រជាក់បន្ទាន់
  • អាចប្រើថ្នាំសំលាប់ផ្សិតនៅដំណាក់កាលលូតលាស់ដូចជំងឺប្លាសដែរ

➢ **ជំងឺឆ្នូតត្នោត** (Narrow Brown Spots)

- **រោគសញ្ញា**
  - ស្នាមមានពណ៌ត្នោតសណ្ឋានជាខ្សែឆ្នូតខ្លីៗស្របសសៃវែនស្លឹក។ អាចកើតលស្រទបស្លឹក និងលើគ្រាប់ដែរ។ ពេលមានសភាពធ្ងន់ធ្ងរ ស្នាមនោះមានទំហំធំ មានពណ៌ត្នោតខ្ចីផ្នែកកណ្ដាលពណ៌ប្រផេះ។ ច្រើនកើតនៅដំណាក់កាលស្រូវមានស្លឹកទង់ជ័យ។
- **ភ្នាក់បង្ករោគ និង ការរាលដាល**
  - ជំងឺបង្កដោយផ្សិតឈ្មោះ Cercospora oryzae
  - ផ្សិតជ្រៀតចូលក្នុងជាលិការុក្ខជាតិតាមរន្ធស្តូម៉ាត និងលូតលាស់ក្នុងកោសិកាអេពីឌែម របស់ស្លឹក។

- **រោគសញ្ញាជំងឺ** លេចឡើងក្រោយពីផ្សិតជ្រៀតចូលបាន ៣សប្តាហ៍។





- **វិធានការការពារ** ដាំពូជដែលធន់នឹងជំងឺ និងធ្វើអនាម័យស្រែ

- **ជំងឺខ្ពស់ដើម** (Bakanae)

  - **រោគសញ្ញា**

    ដើមស្រូវមានទំហំធំជាងដើមស្រូវធម្មតា ស្លឹកធំស្មើងពណ៌លឿងភ្លាវ ។

    ជំងឺលេចឡើងចាប់ផ្តើមពីរលួយគល់រហូតដើមស្រូវងាប់តែម្តង ។

    នៅដំណាក់កាលបែកគុម្ពស្រូវមិនសូវបែកគុម្ព ស្លឹកទង់ជ័យបៃតងព្រលែត ហើយ មានកំពស់ហួសដើមធម្មតា ។

    ស្រូវមិនសូវដាក់គ្រាប់ពេញលេញ ឬអាចផ្តល់សុទ្ធតែគ្រាប់ស្កក ។



- **សរីរាង្គបង្កជំងឺ និង ការរាលដាល**

ជំងឺនេះបង្កដោយផ្សិតឈ្មោះ Fusarium moniliforme ឆ្លងពីដើមមួយទៅដើមមួយទៀតតាមតាមរយៈខ្យល់ និង ទឹក ។

បើជំងឺរាតត្បាតនៅពេលស្រូវចេញផ្កា វាបណ្តាលអោយគ្រាប់កើតជំងឺ ដូចនេះគ្រាប់ជាប្រភពចំលងជំងឺ ។

ការដាក់ជីអាហ្សូតច្រើន និងសីតុណ្ហភាពពី ៣០-៣៥អង្សាសេ ជំរុញអោយកើតជំងឺនេះ

## ➢ វិធានការការពា និង កំចាត់

- ចៀសវាងការយកគ្រាប់ស្រូវកើតជំងឺធ្វើពូជ
- ដាំដុះដោយប្រើពូជធន់
- បំផ្លាញដើមដែលកើតជំងឺចោល
- សំលាប់មេរោគនៅលើគ្រាប់មុនដាំ

- **ជំងឺរលាកស្រទប** (Sheath blight)

- **រោគសញ្ញា**

ជំងឺច្រើនកើតនៅលើស្រទបស្លឹក និងដើម តែអាចកើតនៅលើស្លឹកដែរ ស្នាមលើស្លឹកដំបូងមានរាងពងក្រពើ ឬអេលីបប្រវែងប្រហែល ១ស.ម ពណ៌តងប្រផេះ ហើយរីកធំដល់ ២-៣ស.ម ហើយអាចជួបមុខគ្នា រោគសញ្ញាអាចសង្កេតឃើញនៅពេលស្រូវចេញផ្កា និងពេលទុំ។



- **ភ្នាក់ងារបង្កជំងឺ និង ការរាលដាល**

ជំងឺនេះបង្កឡើងដោយផ្សិតឈ្មោះ  Rhizoctonia solani ផ្សិតរស់នៅក្នុងដី លើស្មៅ (Gramineae) លើកំទេចកំទីរុក្ខជាតិដែលនៅក្នុងស្រែ ។

សំរាប់ការជ្រៀតចូលរបស់ផ្សិតត្រូវការសីតុណ្ហភាព ៣០-៣២ អង្សាសេនិងសំណើមបរិយាកាស ៩៦-៩៧%  ។

- **វិធានការការពារ និង កំចាត់**

  - សំអាតស្មៅ និង កំទេចកំទីរុក្ខជាតិក្នុងស្រែអោយស្អាត
  - ដាំដំណាំឆ្លាស់ និង ដាំដុះពូជធន់
  - ស្ទូងអោយមានចន្លោះគុម្ពទូលាយ(៣0 x ៣0ស.ម ឬ ៤0 x ៤0ស.ម)
  - ការបាចកំទេចអាចម៍រណា ឬអង្កាមអាចបន្ថយការបង្កជំងឺបានមួយកំរិតដែរ
  - សំលាប់មេរោគនៅលើគ្រាប់ពូជមុនដាំដោយប្រើថ្នាំ Benlate ក្នុងកំរិត ២គក្រ/១តោនគ្រាប់ ។

- **ជំងឺសាប៊ុងបៃតង** (False smut)

- **រោគសញ្ញា**

  រោគសញ្ញាលេចឡើងនៅក្រោយពេលចេញផ្កា មីក្រុបលូតលាស់ក្នុងអូវែ គ្រាប់ក្លាយជាដុំពណ៌បៃតងខាងក្រៅ និងលឿងខាងក្នុង កើតឡើងដោយកន្លែងក្នុងស្រែ និងលើគ្រាប់ខ្លះនៃកួរ មានសារធាតុម្យ៉ាងខាប់ស្អិត។




## ➢ សរីរាង្គបង្ករោគ និង ការលូតលាស់

- **ជំងឺបង្កដោយផ្សិតឈ្មោះ Ustilaginoidea virens**

- ស្ព័ររបស់ផ្សិតដុះនៅសីតុណ្ហភាព ១២-១២ អង្សាសេ ប៉ុន្តែសំរាប់ការលូតលាស់សមស្របគឺ ២៨អង្សាសេ និងសំណើមបរិយាកាសចាប់ពី ៩២%ឡើងទៅស្ព័រអាចចំលងទៅរុក្ខជាតិផ្សេងតាមរយៈខ្យល់ (air-born)

## ➢ វិធានការគ្រប់គ្រង

- ដាំពូជដែលធន់នឹងជំងឺ
- រើសគ្រាប់ពូជដែលគ្មានជំងឺយកទៅដាំ
- ពេលប្រមូលផលត្រូវច្រូតដើមដែលមានជំងឺមុន
- សំរាប់មេរោគនៅលើគ្រាប់ពូជមុនដាំ ដោយត្រាំក្នុងសូលុយស្យុងបារ៉ែតក្លរីត ដែលមានកំហាប់ ១/១000 រយៈពេល ៣0នាទី

- **ជំងឺរលួយស្រទបស្លឹក** (Sheath rot)

- **រោគសញ្ញា**

  ច្រើនកើតលើស្រទបស្លឹកដែលនៅខ្ពស់ជាងគេ គឺស្រទបស្លឹកទង់ជ័យចាប់ផ្តើម ពីមានស្នាមទ្រវែងប្រវែង 0,៥-១,៥ស.ម ផ្នែកកណ្តាលពណ៌ប្រផេះ និងគែមពណ៌ត្នោត ឬត្នោតប្រផេះ រួចស្នាមរលាយចូលគ្នា។

  ពេលធ្ងន់ធ្ងរក្តួរស្រូវចេញមិនផុតពីស្រទប ហើយរលួយក្តួរស្រូវដែលចេញផុតផ្នែកខ្លះមិនផ្តល់គ្រាប់ស្រូវល្អពេញលេញ។





- **សរីរាង្គបង្ករោគ និង ការលូតលាស់**

  បង្កដោយផ្សិតឈ្មោះ Acrocylindrium oryzae លូតលាស់នៅពេលអាកាសធាតុក្តៅហើយសើម ។

  ច្រើនកើតនៅលើរុក្ខជាតិដែលមានរបួសដោយសារការបំផ្លាញរបស់សត្វល្អិត ជាពិសេសដង្កូវស៊ីរូងដើម ។

- **វិធានការការពារ**

  មានពត៌មានតិចតួចអំពីវិធានការប្រឆាំងជំងឺនេះ

# ជំងឺបណ្តាលមកពីបាក់តេរី

# (Bacterial diseases)

- **ជំងឺស្រពោនបណ្ដាលមកពីបាក់តេរី (Bacterial blight)**

  - **រោគសញ្ញា**

    សញ្ញាលេចឡើងជាស្នាមបន្ទះវែងៗ ពណ៌ស ឬលឿង សណ្ឋានដូចចំនុចជាំទឹក នៅលើគែមស្លឹក និងតួស្លឹក។ រីករាលដាលលើស្លឹកទាំងមូល ពីលើចុះក្រោម។

    ពេលរាលដាលខ្លាំងប្រែពណ៌ទៅជាប្រផេះ និងរួចក្លាយជាពណ៌ស ស្ងួតងាប់ ពេលព្រឹកមានទឹកសន្សើម ឃើញមានសំបុកបាក់តេរីត្រង់កន្លែងកើតជំងឺ។






* **ភ្នាក់ងាបង្ករោគ និង រាលដាល**

ជំងឺនេះបង្កដោយបាក់តេរីឈ្មោះ Xanthomonas campestris pv.oryzae បាក់តេរីជ្រៀតចូលតាមរន្ធស្តូម៉ាត ស្នាមរបួស តាមឫស លូតលាស់ក្នុងរុក្ខជាតិ ឆ្លងតាមទឹកភ្លៀង ឬការបញ្ជូលទឹក។

អាកាសធាតុក្តៅហើយសើម(២២-៣១ អង្សាសេ)សមស្របសំរាប់ការរាលដាល

ប្រភពចំលង: គល់ជញ្រ្ជាំង គ្រាប់កើតជំងឺ និងទឹកដែលមានមេរោគ។

* **វិធានការការពារ**

ជៀសវាងការយកគ្រាប់ដែលមានជំងឺធ្វើពូជ

បំផ្លាញគល់ជញ្ជ្រាំងដែលកើតជំងឺចោល

ជៀសវាងការបោះបង់កាកសំណល់រុក្ខជាតិដែលកើតជំងឺក្នុងប្រភពទឹកសំរាប់ស្រោចស្រព

## *ជំងឺបាក់តេរីឆ្នូតលើស្លឹក (Bacterial leaf streak)

*** រោគសញ្ញា**

លេចឡើងលើស្លឹកដំបូងមានស្នាមបន្ទាត់ពណ៌សផ្ទះ ចន្លោះសរសៃវែនស្លឹក ក្រោយមកស្នាមប្រែជាពណ៌ត្នោត កាន់តែរីកធំឡើងៗ គ្របដណ្ដប់ស្មើរ ពេញស្លឹក ពេលរាលដាលខ្លាំងស្លឹកទាំងមូលប្រែជាពណ៌ត្នោតហើយងាប់ ហើយមាន លក្ខណៈដូចជំងឺស្រពោនបណ្ដាលមកពីបាក់តេរី ។




## * សរីរាង្គបង្កជំងឺ និង ការរាលដាល

បង្កដោយបាក់តេរីឈ្មោះ Xanthomonas campestris pv. oryzicola

ជ្រៀតចូលតាមស្នាមរបួស ឬរន្ធស្តូម៉ាតរបស់ស្លឹកបាក់តេរីបង្កើតសំបុកជាគ្រាប់តូចៗ រាងមូល ពណ៌លឿង លើស្លឹកកើតជំងឺឆ្លងតាមរយៈខ្យល់ ទឹកភ្លៀង ទឹកដែលបញ្ចូល និងគ្រាប់ពូជដែលផ្ទុកមេរោគបាក់តេរីអាចយកស្មៅ និងស្រូវដុះសារជាជំរកនៅពេល គ្មានដំណាំស្រូវ ។

## *វិធានការការពារ

កុំដាំគ្រាប់ដែលមានផ្ទុកមេរោគ(មានកើតជំងឺកន្លងមក)ត្រូវបំផ្លាញស្រូវដុះសារ និងស្មៅច

# ជំងឺបណ្តាលមកពីវីរុស

# (Viral diseases)

# ជំងឺទូងគ្រោ (Tunggro virus)

*** រោគសញ្ញា**

ស្រូវដុះវេញៗ បែកគុម្ពតិច ស្លឹកប្រែជាបៃតងលឿងរួចទៅជាលឿងទុំ ឬទឹកក្រូច

ការប្រែពណ៌ចាប់ពីចុងស្លឹកហើយរាលទៅគល់ស្លឹកស្រូវមានកួរខ្លី ស្កក ឬចេញមិនផុត ពេញលេញពីស្រទបសឹកស្រូវទទួលការវាតត្បាតនៅដើមវគ្គលូតលាស់ធ្ងន់ជាងនៅចុងវគ្គលូតលាស់(ដែលអាចសង្កេតឃើញរោគសញ្ញានៅពេលស្រូវដុះសារ)





# ភ្នាក់ងារចំលងជំងឺ

ចំលងដោយសត្វមមាចៈ មមាចខៀវ មមាចពព្រុស(មមាចប៉ារ៉ា)

ចំលងដោយជញ្ជក់ដើមកើតជំងឺរួចទៅជញ្ជក់ដើមគ្មានជំងឺ

វីរុសអាចរស់នៅក្នុងខ្លួនសត្វល្អិតបានរយៈពេលតែ៥ថ្ងៃ

បើមមាចជញ្ជក់ច្រើនដងការចំលងជំងឺក៏បានច្រើន

ប្រភពជំងឺ រុក្ខជាតិកើតជំងឺ ស្រូវព្រៃ គល់ជញ្ជ្រាំង ស្រូវដុះសារ និងស្មៅ

# ជំងឺតឿស្មៅ (Grassy stunt)

## រោគសញ្ញា

ស្រូវដុះរេញ បែកគុម្ពច្រើនហួសប្រមាណ ដូចគុម្ពស្មៅ

ស្លឹកតូចខិ រីង ដុះឈរត្រង់ ពណ៌បៃតងលឿង និងមានស្នាមពណ៌ច្រេះ

ស្រូវមិនសូវចេញកួរ បើកួរដែលចេញទំហំតូច គ្រាប់ច្រើនស្កកពណ៌ត្នោតខ្មៅ





# ភ្នាក់ងារចំលង

ចំលងដោយពពួកមមាចត្នោតតូច (Laodelphax stritellus) ដែលមាន បរិមាណប្រហែល៤0% អាចមានលទ្ធភាពចំលងវីរុសបាន

ក្រោយពេលជញ្ជក់១០ថ្ងៃទើបអាចចំលងបាន រហូតដល់ពេលវាងាប់

ជំងឺមិនចំលងតាមពងមមាច ឬគ្រាប់ពូជទេ

ការរាលដាលអាស្រ័យនឹងបរិមាណមមាច និងរុក្ខជាតិកើតជំងឺ

# ជំងឺតឿរញ្ជួស្លឹក (Ragged stunt)

## រោគសញ្ញា

ស្លឹកមានលក្ខណៈ៣យ៉ាងៈ ស្លឹករហែករយ៉េរយ៉ៃ ស្លឹកឡើងរមួល ឡើង ប៉ោងតាមបណ្តោយសសៃវែង

ពេលតាតត្បាតនៅដំណាក់កាលដំបូងស្រូវដុះរេញ្ជូៗ

ការចេញផ្កាយឺត ឯកួរស្រូវចេញពុំរួចទាំងស្រុងពីស្រទបស្លឹក

ស្រូវបែកខ្នែងនៅត្រង់ថ្នាំងដែលខ្ពស់ជាងគេ ហើយខ្នែងនោះចេញកួរតូចៗ



# ភ្នាក់ងារចំលងជំងឺ

ជំងឺចំលងដោយមមាចត្នោតតូច

ក្រោយពីជញ្ជក់ដើមកើតជំងឺមមាចអាចរក្សាវីរុសទុក៣-៣៥ថ្ងៃ (មធ្យម ១៤ថ្ងៃ) នៅក្នុងខ្លួន

វីរុសមិនឆ្លងតាមពងមមាច និងគ្រាប់ពូជទេ

# ជំងឺតឿលឿង (Yellow dwarf disease)

## រោគសញ្ញា

ដើមស្រូវដុះរញេៗ បែកគុម្ពច្រើន

ស្លឹកឡើងពណ៌លឿងចាប់ពីចុងស្លឹកដែលនៅទាបៗមុន និងមានស្នាមអុច ពណ៌ត្នោតដូចច្រេះ

ពេលកើតនៅដើមដំណាក់កាលលូតលាស់ កួរអាចចេញផុតពីស្រទបតិចតួច ណាស់ គ្រាប់ច្រើនស្កក ជួនកាលកួរចេញមិនរួចពីស្រទបស្លឹក



# ភ្នាក់ងារចំលងជំងឺ

ចំលងដោយសារពួកមមាចជញ្ជក់ស្លឹក មានប្រហែល ៧0-៩0% អាចមានលទ្ធភាព

ចំលងវីរុសបាន

មមាចអាចចំលងជំងឺក្រោយពីវាជញ្ជក់បាន២0ថ្ងៃ

មេរោគស្ថិតនៅក្នុងខ្លួនសត្វមមាច ប្រភេទស្មៅជាច្រើន និងក្នុងស្រូវដែលដុះសារ

ក្នុងលក្ខខ័ណ្ឌអាកាសធាតុអំណោយផល(សីតុណ្ហភាពខ្ពស់) រោកសបាអាចលេចឡើង

៣0ថ្ងៃក្រោយពីការចំលង  បើសីតុណ្ហភាពទាបក្រោយរយៈពេល៩0ថ្ងៃ

# វិធានការជាទូទៅសំរាប់គ្រប់គ្រងជំងឺវីរុស

ការលូតលាស់និងរាលដាលជំងឺវីរុសវាអាស្រ័យទៅនឹងកត្តាផ្សេងៗ

ចំនួននៃរុក្ខជាតិជាប្រភពនៃការរស់នៅរបស់វីរុស(hosts)

ចំនួននិងសកម្មភាពនៃសត្វដែលជាអ្នកចំលងជំងឺ

លក្ខខ័ណ្ឌអាកាសធាតុ

ភាពខ្សោយនៃពូជស្រូវដែលងាយទទួលជំងឺ

មធ្យោបាយដែលប្រសើរសំរាប់គ្រប់គ្រងជំងឺវីរុស គឺការការពាររុក្ខជាតិពីការចំលង គួរផ្តោតអារម្មណ៏លើការទប់ស្កាត់ជំងឺមិនអោយឆ្លងនៅដំណាក់កាលដំបូងនៃការលូតលាស់ ព្រោះជាពេលដែលកកើតសត្វល្អិតចង្រៃច្រើន

**វិធានការគ្រប់គ្រង**

កំចាត់សត្វល្អិតជាភ្នាក់ងារចំលង(ពពួកមមាច)នៅដំណក់កាលដំបូងនៃការកកើត ដោយធ្វើការត្រួតពិនិត្យវត្តមានវាជាប្រចាំ

ដករុក្ខជាតិដែលកើតជំងឺ និងស្មៅចេញពីស្រែអោយស្អាត(ករណីជំងឺកើតតិចតួច)

ត្រូវភ្ជួរលប់គល់ជញ្ជ្រាំងក្រោយប្រមូលផល កុំអោយមានសារស្រូវដុះ។

# ជំងឺបណ្ដាលមកពីណេម៉ាតូដ (Nematode diseases)

## ជំងឺណេម៉ាតូដដើម (Stem nematode)

**រោគសញ្ញា និង ភ្នាក់ងារបង្ក**

ការបំផ្លាញអាស្រ័យតាមបំបន់ដាំដុះ និងអាកាសធាតុដែលលក្ខណៈអំណោយផល អាចធ្វើអោយបាត់បង់ទិន្នផលពី ២០%-៩០%

ដំបូងគឺស្នាមអុចៗពណ៌សលើស្លឹកខ្ចី រួចកាន់តែរីកធំលាតសន្ធឹងរហូតស្លឹកចុះទ្រោម ពេលស្លឹកដុះចេញ ស្លឹកខ្លះឡើងកោងក្រង៉ុក

រុក្ខជាតិដុះរេញ១ ដើមរមួល និងការបំផ្លាញកួរ

នៅដំណាក់កាលសំណាប លូតលាស់រេញ១ ស្លឹករមួលទំរង់ខុសធម្មតា

កួរស្រូវចេញមិនផុតពីស្រទបស្លឹក

កួរស្រូវឡើងរមួល ខូចទ្រង់ទ្រាយ ហើយស្កក

បណ្តាលមកពីណេម៉ាតូដ Ditylenchus angustus







## វដ្តជំងឺ និង ការរាលដាល

ណេម៉ាតូដរស់នៅក្នុងដី និង កំទេចកំទីរុក្ខជាតិ

រុក្ខជាតិទទួលជំងឺដំបូងនៅពេលណេម៉ាតូដចូលដល់ចំណុចលូតលាស់នៃសំណាប

ទោតាមការលូតលាស់របស់ស្រូវណេម៉ាតូដឡើងទៅរកជាលិកាខ្ចីៗ

នៅរុក្ខជាតិចាស់វាស្ថិតនៅថ្នាំង  នៅគល់កួរ  និងក្នុងសំបកគ្រាប់

ពេលស្រូវទុំវារមូរជាភ្នែនសត្វពស់ ហើយរស់នៅជាជីវិតក្រាំងលើគល់ជញ្ជ្រាំង

វាកើតខ្លាំងនៅពេលមានសំណើមខ្ពស់ និងមានកាកសំណល់រុក្ខជាតិច្រើនក្នុងស្រែ

ឆ្លងតាមរយៈទឹកហូរកាត់ពីស្រែមួយទៅស្រែមួយទៀត ពិសេសស្រែទឹកជ្រៅ

# វិធានការការពារ

ធ្វើអនាម័យស្រែអោយបានស្អាតស្អៅ និងកំទេចកំទីរុក្ខជាតិ

ដាំដុះដោយឆ្លាស់មុខដំណាំ

ដុត ឬ ភ្ជួរលប់គល់ជញ្ជ្រាំងបន្ទាប់ពីប្រមូលផលរួច

ត្រូវភ្ជួរដីហាលរយៈពេល២-៣ខែមុនដាំដំណាំផ្សេងទៀត

# ជំងឺសចុងស្លឹក (White tip)

**រោគសញ្ញា និងភ្នាក់ងារបង្ក**

អាចអោយបាត់បង់ទិន្នផលពី១០-៥០%

រាតត្បាតនៅតំបន់ត្រជាក់បង្គួរច្រើនជាងនៅត្រូពិច

រោគសញ្ញាសំខាន់គឺចុងស្លឹកឡើងពណ៌ស ស្លឹកពណ៌បៃតងចាស់ជាងធម្មតា

រុក្ខជាតិដុះវេញៗ ក្តួរតូច ហើយមានគ្រាប់តែពីប៉ុណ្ណោះ

គ្រាប់មានទំហំតូច និងទំរង់ខុសធម្មតា

បង្កឡើងដោយណេម៉ាតូដឈ្មោះ Aphelenchoides basseyi

# វដ្តនៃជំងឺ

ដំណាក់កាលបំបូងណេម៉ាតូនៅក្នុងស្លឹកខ្ចីដែលនៅមូល( កំពូលស្លឹក)
ណេម៉ាតូដធ្វើដំណើរនៅលើដី ឬនាំដោយការទឹកហូរទៅរុជាតិដ៏ទៃ
ក្រោយពីបង្កើតជាក្រុម ទៅបំផ្លាញកួរ
អាចរស់នៅក្នុងសំបកគ្រាប់ ឬលើផ្ទៃគ្រាប់ដែលកើតជំងឺ

# វិធានការការពារ

សំអាតគ្រាប់ពូជដោយជ្រលក់ក្នុងទឹកក្តៅ(៥២-៥២ អង្សាសេ)រយៈពេល១៥នាទី

ការដាំស្រូវនៅដើមរដូវអាចបន្ថយការកើតជំងឺ

# ជំងឺណេម៉ាតូដឬស

## រោគសញ្ញា

បំផ្លាញស្រូវនៅលើដីស្ងួត ក្នុងដំណាក់កាលលូតលាស់ដំបូង

ស្លឹកឡើងពណ៌លឿងលាយលឿងទុំ រួចស្ងួតអស់ ឃើញស្នាមលឿងពេញស្រែ

ចេញជាស្នាមពកៗនៅតាមឬស

បំផ្លាញឬស ធ្វើអោយឬសឡើងពណ៌ត្នោត

ដើមស្រូវដុះរេញ បែកគុម្ពតិច ប្រែជាពណ៌លឿង ខ្លះងាប់ ស្រែមានសភាពឆក

# ជំងឺណេម៉ាតូដឫស

## រោគសញ្ញា

បំផ្លាញស្រូវនៅលើដីស្ងួត ក្នុងដំណាក់កាលលូតលាស់ដំបូង

ស្លឹកឡើងពណ៌លឿងលាយលឿងទុំ រួចស្ងួតអស់ ឃើញស្នាមលឿងពេញស្រែ

ចេញជាស្នាមពកៗនៅតាមឫស

បំផ្លាញឫស ធ្វើអោយឫសឡើងពណ៌ត្នោត

ដើមស្រូវដុះរេញ បែកគុម្ពតិច ប្រែជាពណ៌លឿង ខ្លះងាប់ ស្រែមានសភាពឆក



# ជំងឺមិនឆ្លង ឬ បញ្ហាសារធាតុចិញ្ចឹម

# កង្វះអាហ្សូត (Nitrogen defiency)

នៅដំណាក់កាលដំបូងនៃការលូតលាស់ ស្លឹកប្រែជាពណ៌លឿង ឬបៃតងលឿង

ការលូតលាស់មានភាពយឺតយ៉ាវ ការបែកគុម្ពចុះថយ

បើកើតនៅដំណាកលកាលចេញកួរ ចំនួនគ្រាប់ក្នុងកួរថយចុះ

បើនៅដំណាក់កាលដំបូងមាន N គ្រប់គ្រាន់ ហើយក្រោយមកមានកង្វះ-ស្លឹកចាស់ មានពណ៌លឿង ស្លឹកខ្ចីធម្មតា


N DEFICIENCY


NO N
WITH N

# កង្វះផូស្វរ (Phosphorus deficiency)

ស្រូវបែកគុម្ពតិចលូតលាស់យឺត ហើយដាក់គ្រាប់តិច ស្លឹកមានពណ៌បៃតងក្រម៉ៅ ហើយឈរបះទៅលើជាងស្រូវធម្មតា ពូជខ្លះស្លឹកចាស់ៗ ចេញឆ្នូតពណ៌ ក្លាយជាពណ៌លឿងទុំ ឬក្រហមស្វាយ អាចកើតលើដីអាស៊ីតខ្លាំង ដីស៊ុលហ្វាតអាស៊ីត ដីតួប និងដីអាល់កាឡាំង កើតនៅក្នុងស្រែអាស្រ័យដោយទឹកភ្លៀង ច្រើនជាងក្នុងស្រែលិចទឹក





# កង្វះប៉ូតាស្យូម (Potassium deficiency)

ពេលមិនធ្ងន់ធ្ងរ ស្លឹកឡើងពណ៌លឿងពនិ៍បៃតងក្រម៉ៅ បែកគុម្ពតិច រវេញៗ

ក្នុងករណីធ្ងន់ធ្ងរ ស្លឹកចាស់ៗប្រែជាពណ៌លឿងលាយលឿងទុំ រហូតពណ៌ត្នោត

ការប្រែពណ៌ចាប់ពីចុងស្លឹកដល់គល់ស្លឹក និងមានស្នាមងាប់ស្លឹកលេចឡើង

ទំហំនិងទំងន់គ្រាប់ស្រូវអាចចុះថយ

ច្រើនកើតលើដីខ្សាច់ ដីតួប ដីមានសមាសគ្រើម ឬដីសំបូរដោយដីឥដ្ឋភ្ជាប់ K





# កង្វះស្ពាន់ធ័រ (Sulfur deficiency)

ស្លឹកខ្ចីៗជាងគេឡើងចេញពណ៌លឿង បន្ទាប់មកស្លឹកចាស់ៗក៏ប្រែលឿងដែរ ដើមស្រូវលូតលាស់យឺត បែកគុម្ពតិច និងអាចធ្វើអោយខូចដើមស្រូវទាំងមូល កើតមានលើដីខ្សាច់រូបធាតុសរីរាង្គ នៅតំបន់សើម

ការបញ្ចូលទឹកទៅក្នុងស្រែធ្វើអោយកង្វះស្ពាន់ធ័រកាន់តែមានសភាពធ្ងន់ធ្ងរ (វាបំលែងស៊ុលហ្វាតរលាយអោយទៅជាស៊ុលហ្វីតមិនរលាយ)


100
40
SiO2-0
SiO2-40
N-200
IR8-288-3
SiO2-200

# កាពុលជាតិដែក

មានចំណុចតូចៗពណ៌ត្នោតចេញនៅលើស្លឹកទាបៗជាងគេ

ចំណុចចាប់ផ្តើមពីចុងស្លឹក រួចរាលពេញស្លឹកទាំងមូល

ក្រោយមកប្រែជាក្រហមស្វាយ ពណ៌លឿង ឬលឿងទុំ

ក្នុងករណីធ្ងន់ធ្ងរស្លឹកប្រែជាពណ៌ត្នោត ស្លឹកខាងក្រោមងាប់

ការបែកគុម្ពថយចុះ ឬសឡើងគ្រោតគ្រាតមិនដុះចេញច្រើន ហើយមានពណ៌

ត្នោតចាស់

ច្រើនកើតនៅលើដីអាស៊ីត ហើយលិចទឹកព្រមទាំងមានជាតិច្រើនពេក



# កង្វះស័ង្កសី





# ជាតិប្រៃ






# ជាតិអាល់កាឡាំង





# ដីតួបសរីរាង្គ




